| | | |
|---|---|---|
| ក្រសួងយុត្តិធម៌នៃសហរដ្ឋអាមេរិក<br>***ផ្នែកសិទ្ធិពលរដ្ឋ*** | ក្រសួងអប់រំនៃសហរដ្ឋអាមេរិក<br>***ការិយាល័យសិទ្ធិពលរដ្ឋ*** | សេតវិមាន កម្មវិធីផ្តួចផ្តើមស្តីពី<br>ពលរដ្ឋអាស៊ីអាមេរិក និងអ្នករស់លើកោះប៉ាស៊ីហ្វិក |

# ការប្រយុទ្ធប្រឆាំងនឹងការរើសអើងចំពោះសិស្សនិស្សិត AANHPI និង MASSA

ផ្នែកសិទ្ធិពលរដ្ឋនៃក្រសួងយុត្តិធម៌នៃសហរដ្ឋអាមេរិក (CRT) និងការិយាល័យសិទ្ធិពលរដ្ឋនៃក្រសួងអប់រំនៃសហរដ្ឋអាមេរិក (OCR) បានដាក់ឲ្យអនុវត្តនូវច្បាប់ស្តីសិទ្ធិពលរដ្ឋសហព័ន្ធជាសាធារណៈ និងតាមសាលាដែលបានទទួលមូលនិធិពីរដ្ឋាភិបាលសហពន្ធនៅគ្រប់កម្រិតនៃការអប់រំទាំងអស់។ ច្បាប់នេះនឹងការពារសិស្សនិស្សិតទាំងអស់រួមទាំង ពលរដ្ឋអាស៊ីអាមេរិក ជនជាតិដើមហាវ៉ៃ និងពលរដ្ឋនៅលើកោះប៉ាស៊ីហ្វិក (AANHPI) និងសិស្សនិស្សិតជនជាតិឥស្លាម អារ៉ាប់ Sikh និងអាស៊ីភាគខាងត្បូង (MASSA) ពីការរើសអើងលើជាតិសាសន៍ ពណ៌សម្បុរ និងសញ្ជាតិដើម (រួមបញ្ចូលទាំងភាសា និងការចែករំលែកចរិកលក្ខណៈជាតិសាសន៍)។ CRT ក៏បានដាក់ឲ្យអនុវត្តផងដែរនូវការហាមប្រាមការរើសអើងសាសនាក្នុងសាលារដ្ឋ។ សាលាត្រូវចាត់វិធានការភ្លាមៗ និងសមរម្យដើម្បីឆ្លើយតបបណ្តឹងទាក់ទងនឹងការរើសអើង រួមទាំងការបៀតបៀនកេរ្តិ៍ខ្មាស ឬអំពើហិង្សាទៅលើជាតិសាសន៍ ពណ៌សម្បុរ សញ្ជាតិដើម ឬសាសនា។ នៅខាងក្រោមនេះគឺជាឧទាហរណ៍មួយចំនួននៃសកម្មភាព ឬក្នុងករណីខ្លះទៀតគឺអសកម្មភាព ដោយមន្ត្រីបម្រើការងារក្នុងសាលាដែលអាចរំលោភបំពានច្បាប់ដែលបានដាក់ឲ្យអនុវត្តដោយ CRT ឬ OCR៖

- *សិស្សជនជាតិកូរ៉េអាមេរិកបានប្រាប់នាយកសាលារបស់ខ្លួនថា មានសិស្សជនជាតិកូរ៉េមួយក្រុមបានលួចសៀវភៅពុម្ពប្រវត្តិសាស្ត្រអាស៊ីម្តងហើយម្តងទៀត និងបាននិយាយថា នាងមិនមិនមែនជា "ជនជាតិកូរ៉េពិតឡើយ" ពីព្រោះនាងនិយាយតែភាសាអង់គ្លេសប៉ុណ្ណោះ។ នាយកសាលាបានប្រាប់នាងថា ពីព្រោះតែសិស្សដែលរំខានដល់នាងគឺជាជនជាតិកូរ៉េដែរ ដូច្នេះវាប្រាកដជាមានការយល់ច្រឡំគ្នាមិនខាន ហើយក៏មិនបានចាត់វិធានការណាមួយទេ។*
- *សិស្សជនជាតិ Sikh ម្នាក់*ban*ពាក់ឈ្នួតមកសាលា។ គ្រូបង្រៀនម្នាក់បានប្រាប់សិស្សនេះថា គាត់ត្រូវដោះឈ្នួតចេញសម្រាប់សុវត្ថិភាពផ្ទាល់ខ្លួនរបស់គាត់ ដោយហេតុថាមានអំពើហិង្សាថ្មីទៅលើជនជាតិឥស្លាមក្នុងតំបន់នេះ។ សិស្សបានជម្រាបគ្រូបង្រៀនវិញថា គាត់ជាជនជាតិ Sikh។ នៅពេលដែលគាត់បានបដិសេធមិនព្រមដោះឈ្នួតចេញ គាត់ត្រូវបានព្យួរការសិក្សា។*
- *សិស្សម្នាក់មកពីប្រទេសចិនត្រូវបានព្យួរការសិក្សាឲ្យនៅក្រៅសាលា ដោយសារបានរំលោភបំពានក្រមសីលធម៌របស់សាលា។ ពីមុន ពេលដែលបានជួបជាមួយនឹងជំនួយការនាយកសាលាដើម្បីពិភាក្សាគ្នាពីការព្យួរការសិក្សានេះ មាតាបិតារបស់សិស្សបានសូមឲ្យមានអ្នកបកប្រែភាសា ប៉ុន្តែបុគ្គលិករដ្ឋបាលរបស់សាលាមិនបានត្រៀមឲ្យទេ។ នៅពេលដែលមាតាបិតាសិស្សបានមកដល់សម្រាប់ការប្រជុំ គឺគ្មានអ្នកបកប្រែភាសាទេ ហើយជំនួយការសាលាបានចាប់ផ្តើមធ្វើការប្រជុំ។*
- *អំឡុងពេលមេរៀនស្តីពី 9/11 មិត្តរួមថ្នាក់របស់សិស្សអនុវិទ្យាល័យជនជាតិឥស្លាមម្នាក់បានហៅគាត់ថាជាភេរវករ និងប្រាប់គាត់ឲ្យត្រឡប់ទៅប្រទេសរបស់ខ្លួនវិញ។ គ្រូបង្រៀនបានប្រាប់ទៅថ្នាក់ថា គ្រាន់តែជនជាតិឥស្លាមមួយចំនួនប៉ុណ្ណោះដែរជាភេរវជន និងបានសួរទៅសិស្សថា ហេតុអ្វីបានជាជនជាតិឥស្លាមមិនប្រកាសដកខ្លួនចេញពីការវាយប្រហារភេរវកម្មនៃថ្ងៃ 9/11។ សិស្សបានប្តឹងទៅមន្ត្រីបម្រើការងារនៅសាលា ពីពាក្យពេចន៍ដែលគ្រូ និងមិត្តរួមថ្នាក់របស់ខ្លួនបាននិយាយ ប៉ុន្តែមន្ត្រីបម្រើការងារនៅសាលាមិនបានចាត់វិធានការណាមួយដើម្បីឆ្លើយតបឡើយ។*
- *វិទ្យាល័យមួយបានផ្តល់សេវាកម្មសម្រាប់អ្នករៀនអង់គ្លេស (EL) តែមួយប៉ុណ្ណោះទៅកាន់សិស្ស EL ដែលនិយាយភាសាអេស្ប៉ាញ។ នៅពេលដែលសិស្សនិយាយភាសា Punjabi បានស្នើសុំសេវា EL ដើម្បីជួយពួកគេជាមួយនឹងថ្នាក់កម្រិតខ្ពស់ (AP) នាយកសាលាបានប្រាប់ពួកគេថាមិនអាចទទួលទាំងសេវាកម្ម EL និងចូលរៀនថ្នាក់ AP បានឡើយ។*
- *សិស្សជនជាតិអាស៊ីមួយក្រុមត្រូវបានគេវាយ និងចំអកឡកឡើយជារៀងរាល់សប្តាហ៍ក្នុងថ្នាក់កីឡា ដោយសិស្សផ្សេងទៀតដែលនិយាយថា "ជនជាតិអាស៊ីគួរតែពូកែខាងគណិតវិទ្យា មិនមែនកីឡាបាល់បោះទេ។" នៅពេលដែលប្តឹងទៅគ្រូបង្រៀន គាត់បានប្រាប់ថាការឆ្លើយតបដ៏ល្អបំផុតគឺមិនអើពើចំពោះសិស្សដទៃ និងយកចិត្តទុកដាក់លើការធ្វើឲ្យបានល្អក្នុងថ្នាក់កីឡារបស់គេ។*

**នរណាម្នាក់ដែលបានទទួលព័ត៌មានពីការរើសអើងដែលកើតឡើងក្នុងសាលារៀន ត្រូវដាក់ពាក្យបណ្តឹងតាមរយៈ៖**

ផ្នែកសិទ្ធិពលរដ្ឋរបស់ក្រសួងយុត្តិធម៌នៃសហរដ្ឋអាមេរិក
ផ្នែកឱកាសការអប់រំ
អ៊ីមែល៖ education@usdoj.gov
ទូរស័ព្ទលេខ៖ 202-514-4092 ឬ 877-292-3804
TTY: 800-514-0383

ការិយាល័យសិទ្ធិពលរដ្ឋរបស់ក្រសួងអប់រំនៃសហរដ្ឋអាមេរិក
អ៊ីមែល៖ ocr@ed.gov
ទូរស័ព្ទលេខ៖ 202-453-6100 ឬ 800-421-3481
TDD: 800-877-8339
ជំនួយផ្នែកភាសា៖ 800-USA-LEARN (800-872-5327)

**OCR ក៏ផ្តល់ជំនួយបច្ចេកទេសផងដែរដល់សាធារណៈជន ហើយនឹងឆ្លើយតបចំពោះសំនួរនានាស្តីពីកាតព្វកិច្ចរបស់សាលារៀន និងសិទ្ធិរបស់សិស្សនិស្សិត និងមាតាបិតាស្ថិតនៅក្រោមច្បាប់ដែល OCR ដាក់ឲ្យអនុវត្ត។**

**សម្រាប់ព័ត៌មានបន្ថែមអំពីច្បាប់ដែល CRT និង OCR បានដាក់ឲ្យអនុវត្ត រួមទាំងការហាមឃាត់ការរើសអើងទាំងនោះទៅលើពិការភាព និងភេទ (រួមបញ្ចូលទាំងអត្តសញ្ញាណយេនឌ័រ និងភាពមិនស្របគ្នាជាមួយការរើសអើងខាងភេទ) សូមចូលទៅ www.justice.gov/crt/edo និង www.ed.gov/ocr។ [OCR-00093-KM**